ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២០៣ ...សហវ.ក.ប.ក.អគក

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាលដល់គ្រួសារងាយរងហានិភ័យ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រី ក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកត/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើត ក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
nspc.gov.kh / t.me/socialprotectionkh
ទូរសព្ទលេខ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666
gs_nspc@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៦៧ សសរ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ ស្ដីពីអន្តរាគមន៍គាំពារសង្គមដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា
- បានឃើញប្រកាសអន្តរក្រសួងលេខ៤៩៧ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ ស្ដីពីតម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធមិសុខាភិបាល ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយ
- យោងតាមភាពចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងផែនការ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីការពង្រីកវិសាលភាពមូលនិធិសមធមិសុខាភិបាលដល់គ្រួសារងាយរងហានិភ័យ ដើម្បីផ្ដល់ការថែទាំសុខភាព។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រួសារងាយរងហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោមៈ

- **មូលនិធិសមធមិសុខាភិបាល** សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្ដល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាព ដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស។
- **គ្រួសារងាយរងហានិភ័យ** សំដៅដល់គ្រួសារដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងមានភាពងាយរងគ្រោះដែលមានសមាជិកក្នុងគ្រួសារ មួយយ៉ាងតិចក្នុងចំណោម៥ ដូចខាងក្រោមៈ
  - យ៉ាងហោចណាស់សមាជិកគ្រួសារ១នាក់មានពិការភាព
  - យ៉ាងហោចណាស់សមាជិកគ្រួសារ១នាក់មានអាយុចាប់ពី ៦០ឆ្នាំឡើង
  - យ៉ាងហោចណាស់សមាជិកគ្រួសារ១នាក់មានអាយុក្រោម ២ឆ្នាំ
  - សមាជិកទាំងអស់ក្នុងគ្រួសារមានអាយុក្រោម ១៨ឆ្នាំ ឬ
  - ស្ត្រីជាមេគ្រួសារ (ម្នាក់ឯង ឬមេម៉ាយ)។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

## ជំពូកទី ២
## ការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ

**ប្រការ ៤.-**

គ្រួសារងាយរងហានិភ័យក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់អត្តសញ្ញាណដោយប្រើប្រាស់យន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំដែលមានជាធរមាន ដូចមានកំណត់ក្នុងសេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ៦៧ សសរ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២។

**ប្រការ ៥.-**

ក្រសួងផែនការមានភារកិច្ចដឹកនាំ គ្រប់គ្រងនិងសម្របសម្រួលការកំណត់អត្តសញ្ញាណ ការចេញបណ្ណសម្គាល់ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារងាយរងហានិភ័យ ដោយមានមន្ទីរផែនការរាជធានី ខេត្តជាសេនាធិការ។

## ជំពូកទី ៣
## អត្ថប្រយោជន៍

**ប្រការ ៦.-**

គ្រួសារងាយរងហានិភ័យទទួលបានអត្ថប្រយោជន៍ ដូចមានកំណត់ក្នុងតម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល។

**ប្រការ ៧-**

កញ្ចប់សេវាព្យាបាល ការគ្រោងថវិកា និងនីតិវិធីអនុវត្តចំណាយក្នុងប្រកាសអន្តរក្រសួងនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួងលេខ៤៩៧ សហវ/ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨។

**ប្រការ ៨.-**

គ្រួសារងាយរងហានិភ័យត្រូវប្រើប្រាស់សេវាតាមប្រព័ន្ធផ្តល់សេវាពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលសាធារណៈថ្នាក់ទាប ទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ជាង លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

## ជំពូកទី ៤
## ប្រភពហិរញ្ញប្បទាន

**ប្រការ ៩.-**

រាល់ចំណាយលើការផ្តល់សេវាថែទាំសុខភាពតាមមូលនិធិសមធម៌សុខាភិបាលសម្រាប់គ្រួសារងាយរងហានិភ័យត្រូវហិរញ្ញប្បទានដោយថវិកាជាតិ។

## ជំពូកទី ៥
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ ១០.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទីដឹកនាំការតាមដាន ត្រួតពិនិត្យប្រសិទ្ធភាព និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាល។

**ប្រការ ១១.-**

ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គមមានសិទ្ធិចាត់តាំងមន្ត្រីជំនាញពាក់ព័ន្ធចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែង អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ១២.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងសុខាភិបាល ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**សាស្ត្រាចារ្យ ឈាង រ៉ា**

**រដ្ឋមន្ត្រី**
**ក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងផែនការ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ